ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ៣០៣៧ ព.ណ...ភ.ព

ថ្ងៃពុធ ៥រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅឲ្យបានជ្រាបថា៖ ក្នុងយុទ្ធសាស្ត្រជួយជំរុញ និងលើកកម្ពស់ផលិតផលក្នុងស្រុកឲ្យមានការទទួលស្គាល់ និងចូលរួមប្រើប្រាស់កាន់តែទូលាយទូទាំងប្រទេស ក្រសួងពាណិជ្ជកម្មនឹងរៀបចំ "**ពិព័រណ៍ផលិតផលខ្មែរ ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរជុំកាលទី៥ ឆ្នាំ២០២០** ចាប់ពីថ្ងៃទី ០៥-០៨ ខែវិច្ឆិកា ឆ្នាំ២០២០ នៅក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។

ការរៀបចំព្រឹត្តិការណ៍នេះ ក្នុងគោលបំណងតភ្ជាប់ទំនាក់ទំនងសេដ្ឋកិច្ចគ្រប់ប្រព័ន្ធរវាងរាជធានី-ខេត្តទូទាំងប្រទេស ដើម្បីរួមចំណែកដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិឡើងវិញ បន្ទាប់ពីជួបវិបត្តិជំងឺឆ្លងកូវីដ-១៩។ ក្រសួងពាណិជ្ជកម្ម នឹងប្រមូលកៀរគរផលិតផលខ្មែរដែលមានគុណភាពខ្ពស់ សុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ និងមានការវេចខ្ចប់បានល្អត្រឹមត្រូវ អនុលោមតាមស្តង់ដារផលិតកម្មពីគ្រប់ទិសទីនៅទូទាំងប្រទេសមកដាក់តាំងបង្ហាញ និងស្វែងរកដៃគូយកទៅលក់បន្ត។ ក្នុងអំឡុងពេលពិធីនោះផងដែរ ក្រសួងនឹងសហការជាមួយគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយអនុវត្តតាមស្តង់ដារសុខាភិបាលជាតិ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្មសូមអញ្ជើញពាណិជ្ជករ ផលិតករ សមាគមអាជីវកម្ម និងក្រុមហ៊ុនពាណិជ្ជកម្ម ដែលមានបំណងចង់ចូលរួមក្នុងព្រឹត្តិការណ៍ "**ពិព័រណ៍ផលិតផលខ្មែរ**" សូមអញ្ជើញមកបំពេញបែបបទនៅនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ឲ្យបានមុនថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២០ ជាកំណត់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងនាយកដ្ឋានកិច្ចការពិព័រណ៍ ដែលមានទីតាំងស្ថិតនៅជាន់ទីពីរ នៃអាគារទីស្តីការក្រសួងពាណិជ្ជកម្ម អាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០៧៨ ៧៥៥ ៥៥១ ឬ ០៧៧ ៣៣៩ ៤៣៩ ឬ ០៧៧ ៣៣២ ២៣៣ ឬ ០១៧ ៤៩៥ ០៩១

អាសយដ្ឋានអ៊ីមែល៖ ritatong19@gmail.com ឬ neary86@gmail.com ឬ vuthakep@yahoo.com ឬ kdi_mpp@yahoo.com

សម្គាល់៖ ក្រសួងពាណិជ្ជកម្ម សូមរក្សាសិទ្ធិកែប្រែកម្មវិធីរៀបចំព្រឹត្តិការណ៍ខាងលើប្រសិនបើមានការចាំបាច់។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**
អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម
នាយកដ្ឋានកិច្ចការពិព័រណ៍

# ពាក្យសុំចុះឈ្មោះ
## ចូលរួមពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ
## នៃយុទ្ធនាការទិញផលិតផលខ្មែរ ឆ្នាំ ២០២០
នៅខេត្តមណ្ឌលគិរី ចាប់ពីថ្ងៃ០៥-០៨ ខែវិច្ឆិកា ឆ្នាំ២០២០

### ១.ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | |
| ឈ្មោះប្រធានក្រុមហ៊ុន | |
| អាសយដ្ឋានក្រុមហ៊ុន | |
| ទូរស័ព្ទ ឬទូរសារ | |
| អ៊ីម៉ែល | |

### ២.ព័ត៌មានអំពីប្រភេទផលិតផលដែលត្រូវចូលរួមដាក់តាំងបង្ហាញ

| ប្រភេទផលិតផល | | រាយមុខផលិតផល |
|---|---|---|
| កសិផល | ☐ | |
| ជលផល | ☐ | |
| ផលិតផលម្ហូបអាហារ | ☐ | |
| ផលិតផលភេសជ្ជៈ | ☐ | |
| ផលិតផលសិប្បកម្ម | ☐ | |
| ផលិតផលឧស្សាហកម្ម | ☐ | |
| គ្រឿងសង្ហារិម | ☐ | |
| សេវាកម្ម | ☐ | |

### ៣-លក្ខខណ្ឌនៃការចូលរួម

-ត្រូវរៀបចំស្តង់របស់ខ្លួនឲ្យបានរួចរាល់មុន០១ថ្ងៃ នៃថ្ងៃបើកសម្ពោធពិព័រណ៍

-មិនអនុញ្ញាត ឲ្យលក់ផលិតផលផ្សេងៗដែលមិនមានបំពេញនៅក្នុងបែបបទខាងលើ

-មិនអនុញ្ញាត ឲ្យផ្ទេរស្តង់ ឬក៏ទុកស្តង់នៅទំនេរក្នុងរយៈពេលនៃការតាំងពិព័រណ៍

ក្នុងករណីមិនបានអនុវត្តន៍ ដូចបានជម្រាបជូនខាងលើ គណៈកម្មការរៀបចំពិព័រណ៍មានសិទ្ធិបិទស្តង់ ឬរើបរិក្ខារស្តង់មកវិញ ហើយរាល់ការចំណាយសាងសង់ស្តង់ជាបន្ទុករបស់ម្ចាស់ស្តង់។

ខ្ញុំបាទ/នាងខ្ញុំ ជាប្រធាន/តំណាងក្រុមហ៊ុន សូមធានាអះអាង និងគោរពតាមការណែនាំ និងបំពេញតាមលក្ខខណ្ឌតម្រូវរបស់ គណៈកម្មការរៀបចំពិព័រណ៍។ បើខុសពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ប្រធាន/តំណាងក្រុមហ៊ុន**

ហត្ថលេខា/ត្រា

**សម្រាប់មន្ត្រី**
- លេខ៖.......................................................
- ថ្ងៃ ខែ ឆ្នាំ៖...............................ម៉ោង.....................
- អ្នកទទួល៖.................................................